**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក នៃហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយអាវុធមហាប្រល័យ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកដើម្បីអនុញ្ញាតឱ្យបុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកនោះតាមច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពចំពោះការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កកក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះត្រូវបានកំណត់និយមន័យដូចតទៅ៖

**១.ចំណាយមូលដ្ឋាន** សំដៅដល់ការចំណាយចាំបាច់ដែលកើតឡើងសម្រាប់គោលបំណងណាមួយដូចខាងក្រោម៖

- ថ្លៃម្ហូបអាហារ
- បង់ថ្លៃឈ្នួលឬប្រាតិភោគ
- ថ្លៃថ្នាំពេទ្យឬថ្លៃព្យាបាល
- បង់ពន្ធ
- បង់ធានារ៉ាប់រង
- ការបង់ថ្លៃទឹក ភ្លើង ហ្គាស សំរាម
- ការបង់ថ្លៃឈ្នួលវិជ្ជាជីវៈ
- ការចំណាយសមស្របពាក់ព័ន្ធដល់ការផ្តល់សេវាច្បាប់
- ការចំណាយផ្សេងៗទៀតដែលមិនរំលោភទៅនឹងសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

**២.ចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្ម** សំដៅដល់ការចំណាយចាំបាច់នៃការអនុវត្តកិច្ចសន្យាមុនថ្ងៃដែលទ្រព្យសម្បត្តិរបស់បុគ្គលឬអង្គភាពត្រូវបានបង្កកហើយការបង់ថ្លៃនោះមិនរំលោភទៅលើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។

**៣.ចំណាយផ្សេងៗដែលទទួលបានការអនុញ្ញាតនិងស្របតាមសេចក្តីសម្រេចចិត្តនានារបស់អង្គការសហប្រជាជាតិ** សំដៅដល់ការចំណាយដែលមិនរាប់ចូលក្នុងចំណាយមូលដ្ឋានឬចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្មដែលកំណត់ដោយក្រសួងយុត្តិធម៌និងដែលមិនរំលោភលើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិនិងដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ។

## ជំពូកទី២
## ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កក

**មាត្រា៤ .-**

ត្រូវបានអនុញ្ញាតឱ្យបុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកនោះតាមសេចក្តីសម្រេចរបស់តុលាការដើម្បីជានាះ

- ការចំណាយមូលដ្ឋាន
- ការចំណាយលើការបំពេញកាតព្វកិច្ចតាមកិច្ចសន្យាដែលបានធ្វើមុនការដាក់ទណ្ឌកម្ម
- ការចំណាយផ្សេងៗដែលទទួលបានការអនុញ្ញាតនិងស្របតាមសេចក្តីសម្រេចចិត្តនានារបស់អង្គការសហប្រជាជាតិ។

**មាត្រា៥ .-**

បុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកត្រូវដាក់ពាក្យស្នើសុំប្រើប្រាស់និង/ឬចាត់ចែងទ្រព្យសម្បត្តិដែលត្រូវបានបង្កកនោះទៅតុលាការដែលបានចេញសេចក្តីសម្រេចបង្កក។ សេចក្តីសម្រេចបង្កកត្រូវធ្វើឡើងជាទម្រង់ដីកាសម្រេច។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៣ កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ